

# ភាសាខ្មែរ

**សេរីការ : មហាវិថីគ្មានទ្វារ វាបើកច្រកឱ្យអស់ផ្លូវតូចៗចូលបាន**

តាមឯកសារ ផ្សាយដំណឹង របស់គណបក្សសមរង្ស៊ី នៅប្រទេសបារាំង លេខ ១៨៦ បានដកស្រងអត្ថបទពីដើមអម្ពិល, សរសេរថា : « នៅបារិត គេប្រើភាសាវៀតណាម និង អង់គ្លេស ជាផ្លូវការក្នុងពិធីសម្ពោធ កាស៊ីណូ ឈ្មោះ goodluck 9 »។

តើមានអ្វីគួរឲ្យភ្ញាក់ផ្អើលដែរឬទេ? ចំពោះយើងវិញ, យើងមើលឃើញថាខ្មែរយើងទេ ដែលទុកឲ្យយួនមើលងាយភាសាខ្មែរ ដែលជាភាសាជាតិ ជាអត្តសញ្ញាណសំខាន់ នៃជាតិសាសន៍ខ្មែរ។ មិនចាំបាច់ស្វែងរកឧទាហរណ៍ឆ្ងាយឯណាទេ បើយើងមាន អាសយដ្ឋាន « សំបុត្រ e.mail ក្នុងបណ្តាញអ៊ិនធឺណិត, យើងឃើញខ្មែរ, តាមយើងស្មានមើលទៅ សុទ្ធតែចេះខ្មែរ, សរសេរឆ្លងឆ្លើយគ្នា អំពីនយោបាយខ្មែរ ដោយប្រើភាសាបរទេស ជាមធ្យោបាយសំរាប់ប្រស្រ័យទាក់ទងគ្នាទៅវិញទៅមក។ សេចក្តីខាងក្នុង នៃការឆ្លងឆ្លើយគ្នារវាងខ្មែរនឹងខ្មែរនោះ វាមានគុណភាពល្អណាស់ទាំងក្នុងការប្រើភាសាបរទេស និង គំនិតដ៏ឧត្តុងឧត្តម នៃការស្នេហាជាតិ ដែលនាំឲយើងមានការរំភើបចិត្តណាស់ ឃើញការចេះដឹងរបស់ខ្មែរទាំងនោះ។ តែបើយើង យកមកពិចារណាបន្តិច

យើងឃើញថា ការប្រើភាសាបរទេស ជាទូទៅនេះ មានគុណវិបត្តិ ច្រើនជាងគុណសម្បត្តិ បើសិនទុក ការជជែកដូរគំនិតជាតិនេះ នៅក្នុងគោលបំណងចង់ ឲខ្មែរទូទៅ (ប្រមាណ ៩៥% ដែលមិនចេះភាសារបរទេស) បានដឹងឮផងនោះ ហើយអាចមាន លទ្ធភាព ចូលរួមចំណែក ដោយគ្មានឧបសគ្គ នៃភាសា ក្នុងការពិភាក្សាតទល់គ្នាបានផងដែរ។ ការយកភាសាបរទេសមកជាមូលដ្ឋាន នៃសំវាទ[1] ប្រកដជាវា មានប្រសិទ្ធិភាពមានកំណត់តិច ព្រោះខ្មែរយើងភាគច្រើន គាត់មិនបានចេះភាសាបរទេស តែបើទុកការឆ្លងឆ្លើយគ្នានេះ សំរាប់តែជនជាតិបរទេស និង ខ្មែរភាគតិច ដែលចេះភាសានោះ ការប្រើភាសាបរទេស វាជាការប្រសើរនោះហើយ។ យើងធ្លាប់និយាយរួចហើយថា ប្រទេសជិតខាងយើង បញ្ញាជនគេ គេនាំគ្នាឲតម្លៃ ទៅលើភាសាជាតិគេណាស់ ក្រៅពីការទំនាក់ទំនង ក្នុងឆាកអន្តរជាតិដែលចំបាច់ គេត្រូវការប្រើភាសាបរទេស គឺគេតែងតែយកភាសាជាតិគេ ជាយានសំរាប់ធ្វើសន្ទនា មិនតែប៉ុណ្ណោះ គេយកការចេះដឹងក្នុងផ្នែកភាសា និង បច្ចេកទេស ខំបកប្រែគ្រប់គំនិតបរទេសណា ដែលគេយល់ឃើញថា អាចមានអត្ថប្រយោជន៏ ដល់ប្រជាពលរដ្ឋ និង ប្រជាជាតិគេ។ យើងដឹងដែរថា បើប្រជាពលរដ្ឋខ្មែរភាគច្រើន មានការចេះដឹង គឺបញ្ញាជនខ្មែរ ដែលគេតែងតែទុកខ្លួនគេជាបញ្ញាវន្តនោះ

[1] សំវាទ= មូលដ្ឋាន នៃការសន្ទនា។

ច្បាស់ជាមាន កិត្តិយស តាមពន្លឺ នៃការចេះដឹងនេះជាពុំខាន តែបើអ្នកចេះដឹងទាំងនោះ គាត់សរសេរភាសាបរទេស សំរាប់តែមនុស្សមួយក្រុមតូចអាននោះ ហើយប្រជាពលរដ្ឋខ្លួនឯង ភាគច្រើនឥតមានការចេះដឹង អាចឆ្លៀតយកសំណេរនេះ ជារស្មី នៃចំណេះសំរាប់គាត់ គឺប្រកដជាគាត់ ទុកសំណេរ នៃពួកអ្នកចេះដឹងនេះ ជាទំព័រសស្អាតឥតមានតួអក្សរសំរាប់អាន។ ចំណុចនេះ យើងមិនមែនចង់និយាយថា ទាល់តែចេះភាសារខ្មែរ ទើបអាចទុកជាអ្នកស្នេហាជាតិ ឬ មានប្រយោជន៍ដល់ជាតិនោះទេ ប៉ុន្តែគំនិតស្នេហាជាតិ តម្រូវឲអ្នកស្នេហាជាតិនិមួយៗ មានការខំប្រឹងប្រែងការពារតម្លៃជាតិខ្លួនឯង ដូចជា ការប្រើភាសាជាតិជាអាទិ៍។ វាគ្មានភាពថ្លៃថ្នូរអ្វីទេ ក្នុងការនិយាយគ្នាក្តី សរសេរឆ្លងឆ្លើយគ្នាក្តី ក្នុងរឿងជាតិ រវាងខ្មែរនិងខ្មែរដែលចេះភាសាខ្មែរពិតដូចគ្នា ដោយយកភាសាបរទេសជាមូលដ្ឋាន។ យើងនិយាយនេះសំដៅតែខ្មែរណា ដែលគាត់ចេះភាសាខ្មែរពិតប្រកដ ហើយមាន គោលបំណងរួមចំណែក និង ចែកចំណែក នៅក្នុងការពិភាក្សាខាងនយោបាយតែប៉ុណ្ណោះ, ចំពួកខ្មែរណា ដែលមិនចេះភាសាខ្មែរ ឬ ចេះតែពិបាក សរសេរអក្សរខ្មែរ ក្នុងទំព័រអ៊ិនធឺណិត ដូច្នេះ ការប្រើភាសា ដែលគាត់ចេះ ឬ អាចសរសេរស្រួលបាន គឺគ្មានអ្វី ជាកំហុស ឬ ជាបទឧក្រិដ្ឋអ្វីនោះដែរ។ ម្នាក់ៗអាចជួយជាតិ ទៅតាមសមត្ថភាព និង លទ្ធភាពដែល

ខ្លួនមាន។ ការដែល អាចមានគ្រោះថ្នាក់ដល់ជាតិគឺ សេចក្តីព្រងើយកន្តើយ របស់ខ្មែរក្នុងគ្រោះថ្នាក់ជាតិខ្មែរ ដែលកំពុងជួបប្រទេះឯនោះទេ។ យើងត្រូវដឹងថា សរសេរភាសារជាតិ មិនត្រឹមតែខ្មែរ នៅក្នុងប្រទេសខ្មែរទេ, ខ្មែរនៅបរទេស, ខ្មែររស់នៅក្នុងប្រទេសថៃ, ខ្មែរនៅកម្ពុជាក្រោម គាត់អាចមាន លទ្ធភាពអានបានទាំងអស់គ្នា។ ហើយយើងកុំនាំគ្នាមានបារម្ភឲសោះថា ខ្លាចជនជាតិបរទេសគេមិនកោតសរសើរ ពីគំនិតល្អ ដែលខ្លួនមាននោះ ព្រោះថា កាលណាគំនិតល្អ វាមានជោគជ័យខ្លាំងក្នុងសហគមន៍ជាតិ ច្បាស់ជាជនបរទេស ដែលតាមដានរឿងខ្មែរ គេរកខ្មែរអ្នកចេះភាសា មកបកគំនិតខ្លួននោះឲគេអានហើយ ឬ គេខំរៀនភាសាខ្មែរតែម្តង ដើម្បីឲគេក្លាយទៅជាអ្នកឯកទេស ផ្នែកចំណេះខ្មែរ។ សូមកុំនាំគ្នាយល់ច្រឡំច្រាសទៅវិញថា ខ្មែរត្រូវការឲបរទេសជួយ ដូច្នេះត្រូវនាំគ្នាសរសេរភាសាបរទេស ដើម្បីឲគេដឹងឮសិន, រឿងខ្មែរគ្នាឯង ចាំដើងក្រោយ។ គំនិតនេះ ជាគំនិតក្លីទៅវិញទេ បើចង់ឲបរទេសគេជួយ លុះត្រាតែអ្វីមួយ ដែលចង់ឲគេជួយនោះមានប្រជាប្រិយភាពក្នុងជាតិរបស់ខ្លួនសិន គឺថាមានការគាំទ្រពីសំណាក់ប្រជាពលរដ្ឋនោះឯង។ យើងពុំអាចធ្វើនយោបាយ ឥតមាន ប្រជាពលរដ្ឋខ្មែរ បាននោះឡើយ ដូច្នេះត្រូវយកភាសាជាតិ ជាភាសាសំរាប់ផ្សាយគំនិត ដើម្បីឲប្រជាពលរដ្ឋ ងាយស្រួលយល់ផង។ បើមិននាំគ្នា ធ្វើការខំ

ប្រឹងប្រែង ប្រើភាសាជាតិនោះទេ កុំនាំគ្នាខឹងនឹងជនជាតិយួន ដែលគេចេះនិយាយ និង សរសេរភាសាខ្មែរ តែនៅចំពោះមុខខ្មែរ ដែលជាឆ្កែបំរើគេ គេនាំគ្នានិយាយភាសាយួន ព្រោះពួកគេដឹងថា អ្នកដឹងនាំខ្មែរ ច្បាស់ជានាំគ្នាខំប្រឹងរៀនភាសាយួន, បារាំង, អង់គ្លេស ដើម្បីស្រួលងាយបំរើគេ ព្រោះមាន ខួរក្បាលទទេគ្មានអត្តរសជាខ្មែរ។ យើងដឹងថា នៅស្រុកខ្មែរបច្ចុប្បន្ន ចេះនិយាយ និង អានភាសាយួន ជាអំណាចមួយទៅលើអ្នករាជការខ្មែរ ដូចនៅជំនាន់អាណាព្យាបាលបារាំង ពួកថិបកខ្មែរ គាត់មានអំណាចជាងកុម្ស៊ីសេនាធិបតីខ្មែរទៅទៀត ព្រោះគាត់ជាអ្នកបកប្រែភាសាពីខ្មែរទៅបារាំង និង ពីបារាំងមកខ្មែរ, បើគាត់បកខុសគឺ អ្នកនិយាយ គឺពិតជាមានគ្រោះកំណាចដល់ខ្លួនជាមិនខាន។ ការចេះភាសាបរទេសច្រើន គឺពិតជាមានអត្ថប្រយោជន៍ដល់ជាតិ តែបើចេះសំរាប់តែខ្លួនឯង និង សំរាប់តែជនបរទេស គឺប្រាកដជាការចេះដឹងមួយឥតមានខ្លឹមសារអ្វី សំរាប់បំរើជាតិខ្លួនឯងនោះទេ។ រឿងដែលចម្លែកមួយ គឺអ្នចេះភាគច្រើននៅបរទេស គាត់និយាយខ្មែរនៅក្នុងអង្គប្រជុំ តែអត្ថបទ ដែលជាឯកសារស្រាវជ្រាវរបស់គាត់ គឺគាត់សរសេរ ជាភាសាបរទេសទៅវិញ, នាំឲគំនិតគាត់ឋិត នៅក្រោមឥទ្ធិពលបញ្ញាបរទេស ជានិច្ច ដែលជា បង្វៀរ (ហ្វ្រ័ង) មួយក្នុងការស្វែងរកជម្រៅ នៃបញ្ញាខ្មែរ ដែលខ្មែរយើង ធ្លាប់មានក្នុងវប្បធម៌ជាតិ។ យើង

# ភាសាខ្មែរ

ដឹងច្បាស់ណាស់ថា វប្បធម៌ខ្មែរយើង បានទទួលឥទ្ធពលពី វប្បធម៌ឥណ្ឌា តែខ្មែរយើង មានបញ្ញា ចេះធ្វើនវានុវត្តន៍ (បញ្ញូលរបៀបថ្មី) លើអ្វីដែលយើងបានទទួលនោះ ឲក្លាយ ទៅជា វប្បធម៌ថ្មីមួយរបស់ខ្មែរសុទ្ធសាត។ សមត្ថភាពខ្មែរ នៃនវានុវត្តន៍នេះឯង ដែលជាបញ្ញាពិសេសរបស់ខ្មែរ, តែ បញ្ញានេះ វារលាយបែកខ្ញែកអស់ ព្រោះមហាក្សត្រខ្មែរបាន ក្លាយជា បទេសរាជា (ទុនខ្សោយ មានឋានៈជា រណប ប្រទេសដទៃ) អស់ច្រើនសតវត្ស លែងមានប្រាជ្ញាដឹកនាំ ប្រជាជាតិក្នុងមាគ៌ា នៃវឌ្ឍនធម៌ ដែលជាកត្តានាំឲជាតិ ខ្មែរ ធ្លាក់ក្នុងអត្ថង្គត។ ជនជាតិយួននៅបារិត គេនិយាយ ភាសាយួននៅចំពោះមុខមន្ត្រីខ្មែរ ព្រោះគេដឹងថា ពួកមន្ត្រីខ្មែរនៅបារិត សុទ្ធតែមានដើមកំណើតជាយួន, ចេះ និយាយយួន ព្រោះជាមាតាភាសារបស់គេ, តែដល់ខ្មែរចេះ ខ្មែរ នាំគ្នាសរសេរភាសាបារាំង អង់គ្លេស ក្នុងសម័យជាតិ មានគ្រោះដល់អាយុជីវិត, រឿងនេះគួរឲអស់សំណើច, មាត់ ចេះតែនិយាយជានិច្ចថា ស្រឡាញ់ជាតិ តែគំនិតប្រាជ្ញាពួក គេឋិន នៅក្រោមបញ្ញាបរទេសជានិច្ច ព្រោះក្នុងពាក្យនិមួយៗ ដែលជាពាក្យបរទេស វាមានទម្ងន់ខ្លាំងណាស់ ក្នុង គំនិតរបស់ពួកគាត់ តែបើពួកគាត់យល់ឃើញថា ធ្វើបែប នេះគឺជា ការបង្ហាញការចេះដឹងរបស់ពួកគាត់, ការចេះ ដឹងនោះច្បាស់ជា ការចេះដឹង សំរាប់ឲជនជាតិយួន លេប ទឹកដីខ្មែរតែប៉ុណ្ណោះ ព្រោះថា ជនជាតិយួន ដែលជាម្ចាស់

ខ្មែរ ដូចដែលបាន លើកមកនិយាយរួចមកហើយ គេនាំគ្នានិយាយយួនជា មួយខ្មែរ បំរើពួកគេ ដើម្បីឲខ្មែរជំពូកនោះខំប្រឹងរៀនភាសាយួន ដើម្បីបំភ្លេចភាសាខ្មែរ តែផ្ទុយទៅវិញ នៅចំពោះមុខជនបរទេស ពួកគេ នាំគ្នានិយាយខ្មែរដើម្បី ឲជនបរទេសទាំងនោះ ជឿជាក់ថា នៅស្រុកខ្មែរ គតមានយួននៅទេ, មិនតែប៉ុណ្ណោះ មានបងប្អូនខ្មែរយើងរស់នៅបរទេសមួយជំពូក នាំគ្នាទៅលេងស្រុកខ្មែរ ហើយនិយាយថា គាត់អត់ឃើញមានយួននៅស្រុកខ្មែរសោះ, បើមានក៏មានតិចតួចណាស់។ យើងដឹងរួចដែរថា ខ្មែរដូចគ្នា, និយាយខ្មែរដូចគ្នា, មួយនិយាយខ្មែរក្នុងគំនិតយួន, មួយទៀតនិយាយខ្មែរ ក្នុងគំនិតស្នេហាជាតិ, វាពិបាកនឹងយល់គ្នាណាស់ទៅហើយ, ចុះទំរាំខ្មែរអ្នកចេះ ជាអ្នកស្នេហាជាតិនាំគ្នាយកភាសាបរទេស ជាការផ្សាយគំនិតស្នេហាជាតិដល់ប្រជាពលរដ្ឋខ្លួន តើការជជែកគ្នា រវាងខ្មែរនិងខ្មែរ វាពិបាកបែបណាទៅទៀត ដែលមានភាសាជារនាំង។ ក្នុងចំណុចនេះ យើងចង់បញ្ជាក់ថា ការប្រើភាសាខ្មែរ មិនទាន់គ្រប់គ្រាន់ថា ជាអ្នកស្រឡាញ់ជាតិនោះទេ លុះត្រាតែមានចិត្តជាខ្មែរផងទៀតដែរ ទើបភាសាខ្មែរ អាចក្លាយជាអាវុធសំរាប់ការពារជាតិខ្មែរបាន។ ក៏ដូចគ្នានឹងខ្មែរមានចិត្តជាខ្មែរ ចេះខ្មែរច្បាស់ហើយ តែមិនយកភាសាជាតិខ្លួនឯង ជាភាសារបស់ខ្លួន សំរាប់ធ្វើការទាក់ទង រវាងខ្មែរគ្នាឯងនោះដែរ។ យើងដឹងទៀតដែរថា យួនចេះភាសាខ្មែរ

# ភាសាខ្មែរ

ដើម្បី សម្លាប់ខ្មែរ, ឯចំណែកខ្មែរយើង នាំគ្នាបំភ្លេចភាសាជាតិ ដើម្បី ជួយយួនឲសម្លាប់ជាតិខ្លួនឯង។ យើងនិយាយនេះគឺគ្មានគំនិត ប្រកាន់ជាតិសាសន៍នោះឡើយ គឺយើងគ្រាន់តែបង្ហាញការពិតតែប៉ុណ្ណោះ តែបើការពិតនេះ ខ្មែរយើងនាំគ្នា ទុកជារឿងឥតបានការ ចំពោះយើងវិញ យើងយល់ឃើញថា សេរីភាពក្នុងមតិនេះ ជាការប្រគល់កូនសោផ្ទះខ្មែរ ឲយួនកាន់ហើយ។ បើយើងនាំគ្នាអានប្រវត្តិសាស្ត្រខ្មែរ យើងឃើញថា យួនយកកម្ពុជា ក្រោមងាយស្រួលណាស់, ហើយបច្ចុប្បន្ននេះ យួនយកកម្ពុជាកណ្តាល វិតតែស្រួលទៅទៀត ហើយវាហួស ពីការស្មាន របស់ខ្មែរយើងទៅទៀត។ ស្រួលអើយមហាស្រួល !